# ជំពូកទី ១០
# សន្និដ្ឋាន និងអនុសាសន៍

Draft

Draft

# ជំពូកទី១០

## សន្និដ្ឋាន និងអនុសាសន៍

យោងលើលទ្ធផលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ នៃគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូរបស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហឿក (អេស ប៊ី ខេ)** ក្រុមការងារបានធ្វើការសន្និដ្ឋានដូចខាងក្រោម:

**១.** ដីសម្បទាននេះមានទីតាំងស្ថិតនៅក្នុងតំបន់អាងទន្លេមេគង្គផ្នែកខាងកើតរបស់ប្រទេស មានរយៈកម្ពស់ពី ០-១៣៨ម ទួលរបបទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំពី **១២០៦,១-២២២១,៣ម.ម** សីតុណ្ហភាពមធ្យមប្រចាំឆ្នាំគឺ **១៥,៦-២៩,០អង្សាសេ** ហើយមានរដូវប្រាំងវែងជាង៦ខែ។ ដីសម្បទាននេះស្ថិតនៅតំបន់ខ្ពង់រាប មានសណ្ឋានដីស្មើរាបស្មើ ក្នុងនោះដីដែលមានជំរាលធំជាង **៥,៤៤ដឺក្រេ** មានចំនួនតែ **៨០ហិកតា** ប៉ុណ្ណោះលើផ្ទៃដីសរុប។

**២.** ដីសម្បទាននេះមានសិលាមេ ០៧ប្រភេទ ក្នុងនោះ **(១)** Basalt មានទំហំ ៥៣៣ហិកតា ឬស្មើនឹង ៥,៨០ភាគរយ **(២)** Conglomerate, breccia មានទំហំ ៦៩ហិកតា ឬស្មើនឹង ០,៧០ភាគរយ **(៣)** Floodplains មានទំហំ ៤៤៥ហិកតា ឬស្មើនឹង ៤,៥៧ភាគរយ **(៤)** Formation of Sandstone and microbreccia មានទំហំ ៣.៨១៧ហិកតា ឬស្មើនឹង ៣៩,២០ភាគរយ **(៥)** No Classified Rock មានទំហំ ១.៤៤៦ហិកតា ឬស្មើនឹង ១៤,៨៥ភាគរយ **(៦)** Pediments មានទំហំ ២.២២៧ហិកតា ឬស្មើនឹង ២២,៨៧ភាគរយ និង **(៧)** Red Terrace (Red Sandstone) មានទំហំ ១២០០ហិកតា ឬស្មើនឹង ១២,៣២ភាគរយ នៃផ្ទៃដីសរុប។

**៣.** យោងលើលក្ខណៈដើមរបស់ដី និងលក្ខណៈនៃឋានលេខា ដីសម្បទាននេះមានដី០២ប្រភេទគឺៈ **(១)** Grey Hydromorphics មានទំហំ ៨៤២ហិកតា ឬស្មើនឹង ៨,៦៥ភាគរយ និង **(២)** Plinthite Podozols មានទំហំ ៨.៨៩៥ហិកតា ឬស្មើនឹង ៩១,៣៥ភាគរយ នៃផ្ទៃដីសរុប។ យោងតាមលទ្ធភាពផលិតកម្ម ដីក្នុងតំបន់សម្បទាននេះត្រូវបានបែងចែកជា០២ប្រភេទគឺ ដីដែលមានដីជាតិខ្ពស់មានទំហំ ៨២២ហិកតា ឬស្មើនឹង ៨,៤៤ភាគរយ ស្ថិតនៅខាងជើងឆៀងខាងលិចនៃដីសម្បទាន និងដីមានដីជាតិទាបមានទំហំ ៨.៩១៥ហិកតា ឬស្មើនឹង ៩១,៥៦ភាគរយ លាតសន្ធឹងស្ទើរពេញផ្ទៃដីសម្បទានទាំងមូល។

**៤.** យោងតាមការអង្កេតលើចំណាត់ថ្នាក់ទីជម្រាល (Slope Classification) ដីសម្បទាននេះមានទីជម្រាល ០៥ប្រភេទគឺៈ **ចំណាត់ថ្នាក់ទី១ៈ** ០-០,៥៧ដឺក្រេ មានទំហំ ៨.៦៩៨ហិកតា ស្មើនឹង ៨៩,៣៣ភាគរយនៃផ្ទៃដីសរុប ជាសណ្ឋានដីដែលមានលក្ខណៈរាបស្មើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដី ការប្រើប្រាស់ដីតំបន់នេះមានលក្ខណៈទូលំទូលាយ សម្រាប់ដំណាំស្រូវ ដំណាំកសិកម្ម និងព្រៃឈើ។ **ចំណាត់ថ្នាក់ទី២ៈ** ០,៥៨-១,៦៤ដឺក្រេ មានទំហំ ៥៣៨ហិកតា ស្មើនឹង៥.៥២ភាគរយនៃផ្ទៃដីសរុប ជាសណ្ឋានដីដែលមានលក្ខណៈរាបស្មើ មិនតម្រូវឲ្យមានការអភិរក្សទឹកនិងដីទេ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដី ការប្រើប្រាស់ដីតំបន់នេះមានលក្ខណៈទូលំទូលាយ អាចប្រើប្រាស់សម្រាប់កសិកម្ម និងព្រៃឈើ។ ចំណាត់ថ្នាក់ទី៣ៈ ១,៦៥-៣,២៩ដឺក្រេ មានទំហំ ២៦១ហិកតា ស្មើនឹង ២.៦៨ភាគរយ នៃផ្ទៃដី

Draft

សរុប មានលក្ខណៈចោទបន្តិចម្តងៗ ហើយចោទធំជាងចំណាត់ថ្នាក់ទី២ខាងលើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹកនិងដី ការប្រើប្រាស់ដីតំបន់នេះអាចមានលក្ខណៈជាការដាំឈើបែបពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម។ **ចំណាត់ថ្នាក់ទី៤៖** ៣,៣-៥,៤៣ដឺក្រេ ចំនួន ១៦១ហិកតា ស្មើនឹង ១,៦៥ភាគរយនៃផ្ទៃដីសរុប ជាសណ្ឋានដីនេះមានលក្ខណៈចោទល្មម។ សណ្ឋានដីប្រភេទនេះមិនសូវងាយរងភាពរេចរឹលដោយការហូរច្រោះទេ។ ការប្រើប្រាស់ដីតំបន់នេះ គឺសំរាប់ការអភិរក្ស ឬគំរោងដាំព្រៃ (ដាំកៅស៊ូ) ប្រសិនបើអនុវត្តវិធានការអភិរក្សបានខ្ជាប់ខ្ជួន។ **ចំណាត់ថ្នាក់ទី៥៖** ៥,៤៤-៩,១១ដឺក្រេ ចំនួន៨០ហិកតា ស្មើនឹង ០,៨២ភាគរយ នៃផ្ទៃដីសរុប ជាសណ្ឋានដីនេះមានលក្ខណៈចោទបង្គួរ។ សណ្ឋានដីប្រភេទនេះងាយប្រឈមនឹងភាពរេចរឹលដោយការហូរច្រោះ។ ត្រូវប្រើប្រាស់ដីតំបន់នេះ សំរាប់គោលដៅនៃការអភិរក្ស ឬគំរោងដាំព្រៃ តែត្រូវអនុវត្តវិធានការអភិរក្សឲ្យបានខ្ជាប់ខ្ជួន។

**៥.** តាមការពិនិត្យទៅលើផែនទីប្រព័ន្ធផ្លូវទឹក បង្ហាញថា នៅក្នុងតំបន់ដីសម្បទាននេះសម្បូរណ៍ប្រភពទឹកស្រទាប់លើជាមធ្យម ដោយក្នុងនោះមានប្រព័ន្ធទន្លេសំខាន់មួយមានឈ្មោះហៅថា ព្រែកទេវ (ចំណុចនិយាមកា ៦៤៣៦៦៥-១៣៧២៦៧០)។ ព្រែកទេវនេះមានទឹកដក់គ្រប់រដូវកាល មានទំហំប្រមាណ ១៨ម ស្ថិតនៅតាមព្រំខាងកើតហូរសំយ៉ុងចុះមកខាងត្បូង និងហូរចេញផុតពីដីសម្បទាននៅចំណុចភូមិស្រែនននៅជ្រុងខាងលិចចុងខាងត្បូង ហើយហូរចាក់ចូលទៅទន្លេមេគង្គនៅត្រង់ចំណុចនិយាមកា ៦១៤៨៣៣-១៣៦៣២៧៣ ក្នុងចម្ងាយប្រមាណ ២២គ.មពីទីតាំងដីសម្បទាន។ ក្រុមការងារបានពិនិត្យឃើញមានអូរតូចៗចំនួន១០ ដែលអូរទាំងនេះខ្លះមានប្រភពនៅខាងក្រៅ និងខ្លះទៀតមានប្រភពនៅក្នុងដីសម្បទានផ្នែកខាងលិច។ មានដៃអូរតូចៗចំនួន០៥ ដែលជាដៃរបស់ព្រែកទេវ មានឈ្មោះគឺអូរធ្យូង (ចំណុចនិយាមកា ៦៤០៤៤៦-១៣៨១៩៧៨), អូរប្រើម ឬអូរព្រាម (ចំណុចនិយាមកា ៦៣៩៥៧៣-១៣៨១២៦៨), អូរឈ្លូង (ចំណុចនិយាមកា ៦៣៨២៩៦-១៣៧៩៣០១), ព្រែកព្រួស (ចំណុចនិយាមកា ៦៣៨៤៩៨-១៣៧៨៣០៥) និងអូរក្រុង (ចំណុចនិយាមកា ៦៤១៥៦១-១៣៧២៦៧០) ដែលហូរពុះកាត់ព្រំដីសម្បទាននៅភាគខាងជើងឆៀងខាងលិច ខាងលិច និងខាងត្បូង។ នៅខាងក្នុងដីសម្បទាននេះ អូរដែលមានទឹកគ្រប់រដូវ មានប្រវែង ៩៥៩ម៉ែត្រ និងអូរដែលគ្មានទឹកនៅរដូវប្រាំងមានប្រវែង ៥៦.៩៣៣ម៉ែត្រ។

**៦.** នៅក្នុងរយៈពេលនៃការវាយតំលៃអំពីអេកូឡូស៊ី និងពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវទទួលរងការរំខានធ្ងន់ធ្ងរ។ ឈើដែលមានតម្លៃពាណិជ្ជកម្មត្រូវបានដកហូតស្ទើរតែទាំងស្រុងអស់ហើយ។ ឧទាហរណ៍ជាក់ស្តែង បច្ចុប្បន្នប្រជាពលរដ្ឋនៅក្នុងតំបន់កំពុងតែប្រមូលផលឈើធ្វើកប្រភេទឈើលេខ-១ ពីក្នុងព្រៃល្បោះ ដែលការប្រើប្រាស់នេះអាចបញ្ជាក់អំពីការធ្លាក់ចុះដ៏ធ្ងន់ធ្ងររបស់ឈើពាណិជ្ជកម្មនៅក្នុងតំបន់នោះ។ ចំពោះប្រភេទឈើលេខ៣ និងឈើក្រៅលំដាប់ថ្នាក់មាននៅសេសសល់បង្គួរតែក៏ពុំមានអង្កត់ផ្ចិតធំដែរ។ ការសិក្សាអំពីការប្រែប្រួលស្ថានភាពសារពើរុក្ខជាតិក្នុងតំបន់សម្បទាននេះក្នុងចន្លោះឆ្នាំ ២០០២-២០១០ បានបង្ហាញថា: **ឆ្នាំ២០០២** : តំបន់គំរោងវិនិយោគនេះមានសហគមន៍សារព័ន្ធរុក្ខជាតិពីរប្រភេទគឺ ព្រៃល្បោះនិងដីគ្មានព្រៃ។ **ឆ្នាំ២០០៦** : តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបួនប្រភេទគឺ ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃគុម្ពោតស្ងួត និងដីគ្មានព្រៃ។ **ឆ្នាំ២០១០** : តំបន់សម្បទាននេះមានសហគមន៍សារព័ន្ធរុក្ខជាតិបួនប្រភេទគឺ ព្រៃពាក់កណ្តាលស្រោង

Draft

ព្រៃល្បោះ ព្រៃគុម្ពោតស្ងួត និងដីគ្មានព្រៃ។ ដំណើរការប់រែប្រួលនេះមានបង្ហាញជូននៅក្នុងតារាង ៥-៨ ខាងក្រោម៖

**តារាង៥-៨៖ ដំណើរប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគម្របព្រៃឈើរយៈពេល៨ឆ្នាំ**

| ប្រភេទព្រៃ | ២០០២ | ២០០៦ | ២០១០ |
|---|---|---|---|
| ព្រៃពាក់កណ្តាលស្រោង (ហិកតា) | - | ២៩៩ | ២៩៩ |
| ព្រៃល្បោះ (ហិកតា) | ៩២៤៩ | ៨៨៣៤ | ៧០៤៣ |
| ព្រៃគុម្ពោតស្ងួត (ហិកតា) | - | ៧២ | ៧២ |
| ដីគ្មានព្រៃ (ហិកតា) | ៤៨៨ | ៥៣២ | ២៣២៣ |
| **សរុប** | **៩៧៣៧** | **៩៧៣៧** | **៩៧៣៧** |

**៧.** តាមលទ្ធផលនៃវិភាគខ្យល់បង្ហាញថា នៅក្នុងចំណោមប៉ារ៉ាម៉ែត្រទាំង ១៣ ក្នុងនោះមាន $O_3$, CO, $NO_2$, $S_2O$, TSP, $PM_{10}$ និងសម្លេង គឺស្ថិតក្រោមកម្រិតបទដ្ឋានជាតិសម្រាប់ការបំពុលខ្យល់ និងបរិយាកាស។ ដោយឡែកចំពោះប៉ារ៉ាម៉ែត្រ TSP, $PM_1$, $PM_{2.5}$, NOx, $H_2S$, $CO_2$, Solar Radiation នៅមិនទាន់បានកំណត់នៅក្នុងកម្រិតបទដ្ឋានជាតិសម្រាប់ការបំពុលនៅឡើយ។

**៨.** តាមលទ្ធផលនៃវិភាគទឹកអណ្តូងក្នុងការដ្ឋានក្រុមហ៊ុន បានបង្ហាញថា៖ បរិមាណកូលីហ្វម និងបាក់តេរី ដែលពិនិត្យឃើញមាននៅក្នុងទឹកអណ្តូងគឺខ្ពស់ (2.000/0 និង 385/100 ដោយឡែកៗពីគ្នា)។ គុណភាពអ៊ីយ៉ុងអ៊ីដ្រូសែន pH = 6.64/6.50-8.5 ស្ថិតក្នុងចន្លោះស្តង់ដារ។ ភាពចម្លងអគ្គិសនី (EC) គឺមានចំនួន 116.0µs/m/NV ពោលគឺខ្ពស់ជាងកំរិតស្តង់ដា.1 ចំណែកឯថាវរូប០៣ទៀតមានដូចជា: Total Disolved Solid (TDS) និង Total Hardness ($CaCO_3$) មានបរិមាណ 0.00/5.0, 94.00/800.0 and 49.72/300.0 ពោលគឺ មានបរិមាណទាបជាងកំរិតស្តង់ដារ។ ចំណោមថាវរូបគីមី១៥មាន Chloride (Cl), Sulphate ($SO_4$), Flore (F), Nitrite ($NO_2$), Nitrate ($NO_3$), Iron (Fe), Manganese (Mg), Arsenic (As), Copper (Cu), Lead (Pb), Nickel (Ni), Zinc (Zn), Cobalt (Co), Cadmium (Cd) and Mercury (Hg) មានបរិមាណទាបជាងកំរិតស្តង់ដារ។ ដោយឡែក Cobalt មានបរិមាណ 0.003mg/l (ខ្ពស់) ប៉ុន្តែ ថាវរូបនេះនៅមិនទាន់មានកំណត់នៅក្នុងកម្រិតស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិរបស់ក្រសួងឧស្សាហកម្ម និង សិប្បកម្មនៃព្រះរាជាណាចក្រកម្ពុជាទេ។

**៩.** បរិមាណ TSS និង TN មានកម្រិតខ្ពស់ជាងបទដ្ឋាន ស្តង់ដារទឹកនៅតាមតំបន់ទឹកសាធារណៈសម្រាប់អភិវឌ្ឍន៍ជីវៈចំរុះនៅក្នុងទឹក និងការពារសុខភាពសាធារណៈរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ លទ្ធផលវិភាគទឹកបង្ហាញថា TSS នៅក្នុងសំណាកទី ២-៥ មានចំនួន ៥៣-៣.៥ដង ចំណែកឯ TN នៅក្នុងសំណាកទី២ មានចំនួន ១៣,៥-២.២៥ដង ច្រើនជាង។ កំណើនបរិមាណថាវរូបទាំងពីរនេះនៅក្នុងសំណាក់ទឹកអាចពន្យល់បានថា ដោយសារការយកសំណាកទឹកនៅក្នុងរដូវវស្សា (ការហូរច្រោះនាំទឹកឡើងករកល្អក់) និងការប្រើប្រាស់ជីអាសូតលើសកម្រិត។

**១០.** ដីរបស់ក្រុមហ៊ុន **ដូទីសាយហ្គុន-ប៊ិញហ្វឿក (អេស ប៊ី ខេ)** ជាទូទៅមាន សណ្ឋានជាដីដែលកំណត់អំពីកម្រិតនៃការចាក់ឫស ការរីកធំធាត់របស់ឫស លទ្ធភាពក្សាដី និងទឹក ការដកដង្ហើមរបស់ដី ដូចជាមាន

Draft

បរិមាណគ្រួសច្រើន, ជាដីបៀមទឹក សម្បូរណ៍ថ្មរីង (Plinthite or Laterite) ហើយនិងនៅកន្លែងមួយចំនួនជាដីដែលមានល្បាយខ្សាច់ច្រើន។ យោងលើភាពសមស្របសម្រាប់ដំណាំកៅស៊ូ ដីក្នុងតំបន់នេះ ត្រូវបានបែងចែកជា ០៦ប្រភេទ ភាគច្រើនជាដីទាមទារឲ្យមានការកែលម្អ (Amelioration Potential), ត្រូវការប្រព័ន្ធរំដោះទឹក ដី និងប្រឈមនឹងការហូរច្រោះ។ ក្នុងដីទាំង០៦ចំណាត់ថ្នាក់នេះ ដីមានលក្ខណៈសមស្របជាងគេគឺស្ថិតនោះក្នុងចំណាត់ថ្នាក់ប្រភេទ **B** និង **C1**។ ប៉ុន្តែដីទាំង០២ប្រភេទនេះ មានទំហំសរុបប្រមាណតែ ៥០០ហិកតា ក្នុង០១ប្រភេទប៉ុណ្ណោះ ហើយដីទាំង០២ប្រភេទនេះ មានសណ្ឋានជាជម្រាលដែលមានមុំទាបទៅទាបមធ្យម។ ដីដែលមានស្រទាប់ជ្រៅ ពិនិត្យឃើញមាននៅផ្នែកពាយ័ព្យ និងផ្នែកខាងជើងរបស់ដីសម្បទាននេះ ហើយជាដីដែលមានសណ្ឋានរាបស្មើ និងមិនទាន់ទទួលការសឹកដាច់ឬហូរច្រោះនៅឡើយទេ។ ដីនេះមានទំហំប្រមាណជា ១៥ភាគរយនៃផ្ទៃដីសរុបដែលបានអង្កេត។ ដីដែលមានចំណាត់ថ្នាក់ជាប្រភេទ **C2** មានទំហំសរុបប្រមាណជា ៥ភាគរយនៃផ្ទៃដីដែលបានអង្កេត ហើយស្ថិតនៅរាយប៉ាយនៅទូទាំងតំបន់សិក្សា។ ដីប្រភេទ **C2** ដែលមានទំហំធំគឺ ៧១ហិកតា ស្ថិតនៅផ្នែកខាងកើតនៃដីដែលទើបតែឈូសសម្អាតហើយថ្មីៗ។ ដីដែលមានចំណាត់ថ្នាក់ជាប្រភេទ **D** និង **E** ភាគច្រើនជាដីរាបស្មើហើយលាតសន្ធឹងរហូតដល់ព្រំខាងលិចរបស់ដីសម្បទាន (មានទំហំសរុបប្រមាណជា ២៥ភាគរយ)។

**១១.** ការសិក្សាអំពីសារព័ន្ធរុក្ខជាតិនៅក្នុងតំបន់សម្បទាននេះបង្ហាញថា មានរុក្ខជាតិប្រមាណ ៧១ ប្រភេទជាឈើខ្ពស់ៗ និង២៩ប្រភេទ ជារុក្ខជាតិស្រទាប់ចម្រុះ មានដូចជាពពួកមើម វល្លិ ស្មៅ និងស្បូវជាដើម ដែលក្រុមការងារបានជួបប្រទះ និងកត់ត្រានៅក្នុងឡូត៍-អនុឡូត៍គម្រូទាំងអស់។ ក្នុងចំណោមឈើទាំង ៧១ប្រភេទនេះមាន ៤៦ប្រភេទ នៅក្នុងព្រៃល្បោះ ៣៨ប្រភេទ ក្នុងព្រៃពាក់កណ្តាលស្រោងរេចរឹល និង ២៨ប្រភេទ នៅក្នុងព្រៃតាមដងអូរ។ មានឈើចំនួន ១៨ប្រភេទ ក្នុងចំណោមឈើ ៧១ប្រភេទ ត្រូវបានចាត់ទុកថាជាប្រភេទឈើពាណិជ្ជកម្ម។ ប្រភេទឈើទាំង ១៨ប្រភេទនេះរួមមាន៖ ឈើប្រណិត ០៥ប្រភេទ ឈើលេខ១ ០៦ប្រភេទ ឈើលេខ២ ០៣ប្រភេទ និង ឈើលេខ៣ ០៤ ប្រភេទ។ ក្រៅពីនេះ នៅមានប្រភេទឈើប្រមាណជា ២០-២៥ប្រភេទ ផ្សេងទៀត ដោយរាប់បញ្ចូលទាំងប្រភេទឈើក្រៅលំដាប់ថ្នាក់ទៀតនោះត្រូវបានប្រើប្រាស់ជាញឹកញាប់សម្រាប់ជាឈើគ្រឿងសំណង់ដូចជា ធ្វើសសរ ក្តារបន្ទះ ឬគ្រឿងសង្ហារឹមជាដើម។

**១២.** ការសិក្សាបានបង្ហាញថា មានសុកុណជាតិចំនួន៧៩ប្រភេទ ដែលមានចំនួន៣៩១ក្បាល និងតាមរយៈដានជើង លាមក និងស្នាមកាយ ពិនិត្យឃើញមានថនិកសត្វចំនួន០៤ប្រភេទ មានប្រើស ឈ្លូស ជ្រូក និងសំពោច។

**១៣.** ព្រែកទេរមានត្រីសរុបចំនួន ១៦៥ប្រភេទ ដែលបែងចែកជា ៨៥ពួកផ្សេងគ្នា (តាមលទ្ធផលសម្ភាសន៍ និងការការចាប់ជាក់ស្តែង)។ ប្រភេទត្រីទាំងត្រូវបានបែងចែកជា ប្រភេទត្រីប្រផេះ ត្រីខ្មៅ និងត្រីស ហើយប្រភេទត្រីប្រផេះមានចំនួនច្រើនជាងគេ ដែលមានចំនួនរហូតដល់ ១០២ប្រភេទ។ ប្រភេទត្រីដែលស្ថិតនៅក្នុងអំបូរ CYPRINIDAE មានច្រើនជាងគេនៅតាមព្រែកទេរ។ ក្នុងចំណោមប្រភេទត្រីទាំងអស់មានប្រភេទត្រីចំនួន៦ប្រភេទដែលកម្រនឹងប្រទះឃើញគឺ ត្រីថ្ព *(Pristis microdon)* ត្រីឆ្កុកព្រុយខ្លី

Draft

(*Anguilla Bicolor*) ត្រីច្លុក (*Anguilla marmorata*) ត្រីក្របីមានពីរប្រភេទ (*Bagarius suchus* និង *Bagarius yarrelli*) និងត្រីអណ្ដែងងាំង (*Clarias nieuhofi*)។

**១៤.** ប្រជាជនមូលដ្ឋានធ្វើការនេសាទជាលក្ខណៈគ្រួសារ នៅរដូវទឹកឡើង និងរដូវទឹកសំរកនៅខែវិច្ឆិកា។ ភាគច្រើនពួកគាត់ប្រើប្រាស់សំណាញ់ និងមងដែលមានទំហំសំណាញ់ចាប់ពី ២,៥-៥,៥ សង់ទីម៉ែត្រ ដែលមានប្រវែងតិចបំផុត១០ម៉ែត្រ និងប្រវែងវែងបំផុត ៨០ម៉ែត្រ។ ក្រៅពីនេះ ពួកគាត់ប្រើប្រាស់ឧបករណ៍ផ្សេងទៀតមានដូចជា សន្ទូច ថ្នង លប និងទ្រូ។ តាមរយៈធ្វើការសំភាសន៍បានឲ្យដឹងថា ពួកគាត់នេសាទត្រីជាលក្ខណៈគ្រួសារគ្រាន់តែហូបប៉ុណ្ណោះ ដោយមិនបានលក់នៅទីផ្សារឡើយ។

**១៥.** យោងតាមឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ ក្នុងចំណោមប្រជាពលរដ្ឋសរុប ២.១០៥ គ្រួសារ ស្មើនឹង ១០.៩៨៣នាក់ (ស្រី ៥.៤៤៤នាក់ ស្មើនឹង ៤៩,៥៧%) មានជនជាតិភាគតិចព្នងចំនួន ៦៥៧គ្រួសារ ស្មើនឹង ៣.៤២៦នាក់ (៣១,១៩%) ជនជាតិកួយមាន ៨៩៣គ្រួសារ ស្មើនឹង ៤.៤៩១នាក់ (៤០,៨៩%) និងខោញមាន ១៦៦គ្រួសារ ស្មើនឹង ៧៥៣នាក់ (៦,៨៦%)។ តាមឯកសារព័ត៌មានស្ដីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បានឲ្យដឹងថា ក្នុងចំណោមប្រជាពលរដ្ឋសរុប ១.៤៨៣គ្រួសារ ស្មើនឹង ៦.៨៦៥នាក់ (ស្រី ៣.៣៩១នាក់ ស្មើនឹង ៤៩,៤០%) មានជនជាតិដើមភាគតិចព្នងចំនួន ៣៦៩គ្រួសារ ស្មើនឹង ១.៩០១នាក់ (២៧,៦៩%) រស់នៅ និងមិនមានជនជាតិកួយ និងខោញឡើយ។ ជនជាតិដើមភាគតិច និងជនជាតិខ្មែរ ដែលរស់នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន គោរពសាសនា និងប្រតិបត្តិប្រពៃណីរៀងៗខ្លួន ទៅតាមទំនៀមទំលាប់ពីដូនតា ហើយពុំមានជម្លោះក្នុងការប្រកាន់ពូជសាសន៍នោះទេ បើទោះជាគេរស់នៅលាយឡំចម្រុះគ្នាក៏ដោយ។ មិនត្រឹមតែប៉ុណ្ណោះទេ ជនជាតិដើមភាគតិចទាំងនេះមានរបរចិញ្ចឹមជីវិតដូច ឬប្រហាក់ប្រហែលនឹងជនជាតិខ្មែរដែរ និងជាពិសេសមានចំណងអាពាហ៍ពិពាហ៍មួយចំនួន គឺត្រូវបានធ្វើឡើងរវាងជនជាតិខ្មែរ និងជនជាតិដើមភាគតិចទាំងនោះទៀតផង។

**១៦.** យោងតាមការវិភាគនូវស្ថានភាពជីវភាពរស់នៅរបស់គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានបង្ហាញថា នៅក្នុងឃុំថ្មី គ្រួសារដែលរស់នៅលើផ្ទះដំបូលប្រក់ស្បូវមានចំនួន ៥៣,៤០% លើផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូមាន ១៧,៤៨% (ក្នុងនោះលើផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ១,០%) នៅលើផ្ទះដំបូលប្រក់ក្បឿងមាន ២៩,១២%។ ចំណែកឯនៅក្នុងឃុំកន្ទួតវិញ គ្រួសារដែលរស់នៅលើផ្ទះដំបូលប្រក់ស្បូវមានចំនួន ២៨,៧% នៅលើផ្ទះដំបូលប្រក់ស័ង្កសី/ហ្វីប្រូមាន ៣៩.៧% (ក្នុងនោះលើផ្ទះដំបូលប្រក់ស័ង្កសីតិចជាង២០សន្លឹកមាន ៤,០%) នៅលើផ្ទះដំបូលប្រក់ក្បឿងមាន ៣១,២% នៅលើផ្ទះថ្មមិនមែនបេតុងមាន ០,៣% និងនៅលើផ្ទះថ្មល្វែងមាន ០.១%។

**១៧.** តាមលទ្ធផលពីការសម្ភាសន៍បានបង្ហាញថា ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រជាជនប្រមាណជា ២៥,៣% ប្រើប្រាស់ប្រភពទឹកចម្បងដើម្បីចំអិនអាហារពីទឹកអណ្ដូងស្នប់, ២២,៨% ពីអណ្ដូងជីកមានគម្រប, ១,៩% ពីអណ្ដូងជីកគ្មានគម្រប, ៤៣,៨% ពីព្រែកទេរ (សំរាប់ប្រជាពលរដ្ឋនៅភូមិអាលច ភូមិស្រែនន និងភូមិឡៀរ), ៣.១% ប្រើទឹកភ្លៀង និង៣,១% ទិញទឹករទេះឯកជន។ ដោយឡែកសម្រាប់ការប្រើប្រាស់ទូទៅ បោកគក់ ងូត និងបរិភោគវិញ ពួកគាត់ ៣០,២% ទៅដងពីអណ្ដូងស្នប់, ១៩,៨% ដងពីអណ្ដូងជីកមាន



Draft

គម្រប, ០,៦% ដងពីអណ្តូងជីកគ្មានគម្រប, ៤៥,៧% ដងពីព្រែកទេរ ស្រះ ឬត្រពាំង ឬអាងទំនប់ទឹក, ១,២% ពីការត្រងទឹកភ្លៀងទុក និង២,៥% ពីការទិញទឹករទេះឯកជន។ ចំពោះការដាំទឹកឲ្យឆ្អិនមុនបរិភោគ ត្រូវបានបញ្ជាក់ពីមេឃុំទាំងពីរថានៅមានកម្រិតទាបជាង ៣០% នៅឡើយ។

**១៨.** សម្រាប់ប្រជាពលរដ្ឋនៃឃុំថ្មី ដែលរស់នៅតំបន់ខាងក្នុងឆ្ងាយពីផ្លូវជាតិ គឺមិនមានបណ្តាញអគ្គិសនីរដ្ឋ ឬឯកជនចូលទៅដល់ឡើយ។ តាមការវិភាគទិន្នន័យក្នុងឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បង្ហាញថា គ្មានផ្ទះប្រជាពលរដ្ឋណាមួយ ដែលមានតភ្ជាប់នូវបណ្តាញអគ្គិសនីសម្រាប់បំភ្លឺទាល់តែសោះ។ ភាគច្រើនផ្ទះពួកគាត់ចំនួន ១.៤៥៨ខ្នង (៧៣,៤១%) ប្រើប្រាស់អំពូលអាគុយ និងមានផ្ទះចំនួនតែ ៥ខ្នង ប៉ុណ្ណោះដែលប្រើប្រាស់បន្ទះសូឡាទាញយកថាមពលព្រះអាទិត្យសម្រាប់បំភ្លឺនៅពេលយប់។ ដោយឡែក នៅក្នុងឃុំកន្ទួតវិញ ដោយសារពួកគាត់រស់នៅតាមបណ្តោយផ្លូវជាតិលេខ៧ ដូចនេះគឺមានបណ្តាញអគ្គិសនីរដ្ឋទៅដល់ ប៉ុន្តែអ្នកដែលមានលទ្ធភាពតភ្ជាប់បណ្តាញនេះមានចំនួនតិចតួចបំផុត។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ ២០១៤ បង្ហាញថា មានផ្ទះរបស់ពលរដ្ឋចំនួនតិចតួចគឺ ១៨៣ខ្នង ស្មើនឹង ១៤,៨% ប៉ុណ្ណោះមានលទ្ធភាពតបណ្តាញអគ្គិសនីប្រើប្រាស់។ ក្រៅពីនេះ ផ្ទះពលរដ្ឋភាគច្រើនគឺ ៧៤៧ ខ្នង ស្មើនឹង ៦០,៤% ប្រើអំពូលអាគុយសម្រាប់បំភ្លឺនៅពេលយប់។

**១៩.** យោងតាមលទ្ធផលនៃការសម្ភាសន៍គ្រួសារប្រជាពលរដ្ឋក្នុងឃុំទាំងពីរ បានឲ្យដឹងថា ពួកគាត់ស្ទើរទាំងអស់គ្នាប្រើអុស ឬធ្យូងសម្រាប់ការចំអិនអាហារ។ ប្រជាជនក្នុងតំបន់នោះ ៨៨,៥% ប្រើអុសជាប្រភពថាមពលសំខាន់ក្នុងការចំអិនម្ហូបអាហារ ហើយ ១០,៤% ប្រើធ្យូង និងមានតែ ១% ប៉ុណ្ណោះដែលមានលទ្ធភាពប្រើហ្គាស។

**២០.** យោងតាមលទ្ធផលនៃការសម្ភាសន៍ បានឲ្យដឹងថា ប្រជាជនមានដីស្រែស្ថិតនៅខាងក្រោយភូមិករបស់ខ្លួន ចំណែកដីចំការស្ថិតនៅប្រមាណ ២គ.ម ទៅ ៣គ.មពីផ្ទះ។ ប្រជាជនភាគច្រើន (៧៦,៣%) មានដីចំការតែមួយកន្លែងតែប៉ុណ្ណោះ ហើយ ២០% ទៀតមានដីពីរកន្លែង ២,២% មានដីចំការបីកន្លែង និង១,៥% មានដីបួនកន្លែង ហើយប្រជាជននៅតំបន់នោះមានដីស្រែចំការជាមធ្យមទំហំ២,៣ហិកតាក្នុងមួយគ្រួសារ។ ប្រជាពលរដ្ឋនៅភូមិត្នោតមានទំហំដីតូចជាងគេ ដែលជាមធ្យមមានទំហំ ១,៨ហិកតា ស្របពេលដែលអ្នកភូមិស្វាយជ្រុំមានដីស្រែដែលមានទំហំធំជាងគេគឺ ២,៨ហិកតា។ ចំណែកឯអ្នកភូមិផ្សេងៗទៀតមានដីស្រែទំហំប្រហាក់ប្រហែលនឹងអ្នកភូមិស្វាយជ្រុំដែរ គឺអ្នកភូមិអាលចមានដីជាមធ្យម ២,៥ហិកតា ភូមិថ្មីមាន ២,៤ហិកតា ភូមិក្រសាំង និងរៀងមានដីទំហំមធ្យម ២,២ហិកតាក្នុងមួយគ្រួសារ។

**២១.** ប្រជាពលរដ្ឋភាគច្រើន (៦៣%) មានមុខរបរទី១គឺរបរកសិកម្ម ដូចជាធ្វើស្រែ និងចំការ ដោយសារតែគាត់មានដីកសិកម្ម ដីស្រែចម្ការសម្រាប់បង្កបង្កើនផលជាប្រចាំ ជាជាងទុកដីឲ្យនៅទំនេរ។ ពីមុខរបរទី១នេះ ពួកគាត់អាចរកចំណូលជាមធ្យមបានប្រមាណជា ៦៨ដុល្លាអាមេរិក/ខែ។ ក្រៅពីមុខរបរទី១នេះ ប្រជាពលរដ្ឋមួយចំនួនក៏មានមុខរបរទី២ ដើម្បីរកនូវប្រាក់កម្រៃផងដែរ។ ជាក់ស្តែង ពួកគាត់ចំនួន ៤៧,៧% មានចំណូលទី២ពីការលក់កម្លាំងពលកម្ម ហើយជាទូទៅ ប្រជាពលរដ្ឋទទួលបានចំណូលជាមធ្យមពីប្រភពទី២នេះប្រហែល ១១៧ដុល្លាអាមេរិកក្នុង១ខែ។ លើសពីនេះទៅទៀត ពួកគាត់ខ្លះទៀតនៅមានចំណូលដែលបានមកពីមុខរបរបន្ទាប់បន្សំ (ប្រភពចំណូលទី៣) ដែលភាគច្រើនគឺបានមកពីការចិញ្ចឹម



Draft

សត្វគោក្របី ហើយការចិញ្ចឹមគោក្របីរបស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះ មិនប៉ះពាល់ដល់មុខរបរទី១ និងទី២របស់ពួកគាត់ទេ គឺពួកគាត់ព្រលែងវាចោលទៅក្នុងព្រៃឲ្យវារកស្មៅស៊ីដោយសេរីតែម្តង ទាល់តែដល់រដូវភ្ជួររាស់ ឬត្រូវការលក់ ទើបពួកគាត់ទៅកៀងវាពីព្រៃមកវិញ។ ជាមធ្យមពួកគាត់ទទួលបានចំណូលពីប្រភពទី៣នេះប្រហែល ៧៩ដុល្លាអាមេរិកក្នុង១ខែ។ ក្រៅពីនេះ ពលរដ្ឋមួយចំនួនដែលមិនសូវមាន ឬគ្មានដីសម្រាប់បង្កបង្កើនផលមានមុខរបរជាការធ្វើជំនួញខ្នាតតូច (លក់ដូរ និងសិប្បកម្ម) នៅក្នុងសហគមន៍, លក់កំលាំងពលកម្ម (ស៊ីឈ្នួលកាប់ឫស្សី និងដឹកឈើ), ប្រមូលអនុផលពីព្រៃឈើ ហើយមានប្រជាជនតិចតួចធ្វើជាអ្នកនេសាទ និងខ្លះទៀតចិញ្ចឹមសត្វដូចជា ជ្រូក មាន់ ទា ជាដើម។ ជ្រូករស់មួយក្បាលអាចលក់បានតំលៃពី ៤០ម៉ឺន ទៅ ៤៥ម៉ឺនរៀល ឬថ្លៃ ៩,០០០រៀលក្នុងមួយគីឡូក្រាម ឯមាន់ និងទា អាចលក់បានតំលៃ ១៨;០០០-២០,០០០រៀលក្នុងមួយគីឡូក្រាម។

**២២.** បើតាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ ២០០៩ បានបង្ហាញថា ចំណាយសរុប ឬកំរិតបន្ទាត់នៃភាពក្រីក្រ (Net Consumption Expenditure or Poverty Rate) និងចំណាយសម្រាប់អាហារ ឬកំរិតបន្ទាត់នៃភាពក្រីក្រសម្រាប់អាហារ (Food Consumption Expenditure or Food Poverty Line) គឺមានលក្ខណៈ ដូចគ្នានៅក្នុងប្រទេសកម្ពុជាទាំងមូលពោលគឺ ៤៣១៤.៧៥រៀល/ម្នាក់/ថ្ងៃ ចំពោះ Poverty Line និង២៧៧៨,៧០រៀល/ម្នាក់/ថ្ងៃ ចំពោះ Food Consumption Expenditure or Food Poverty Line។ តាមលទ្ធផលនៃការសិក្សា ប្រជាពលរដ្ឋក្នុងឃុំពាក់ព័ន្ធទាំងពីរមានប្រាក់ចំណូលមធ្យម ប្រចាំថ្ងៃចំនួន ៦៥៥៤,៩៣រៀល/ម្នាក់/ថ្ងៃ។ ដូចនេះ បើយើងប្រៀបធៀបទៅនឹងកំរិតបន្ទាត់នៃភាពក្រីក្រឆ្នាំ ២០០៩ ដែលមានត្រឹមតែ ៤៣១៤,៧៥រៀល/ម្នាក់/ថ្ងៃ នោះយើងអាចសន្និដ្ឋានបានថា នាពេលបច្ចុប្បន្នកំរិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់នោះល្អប្រសើរជាងមុន ដោយសារពួកគាត់មាន ប្រាក់ចំណូលប្រមាណជា ២២៤០,១៨រៀល/ម្នាក់/ថ្ងៃ កើនលើសកាលពីឆ្នាំ ២០០៩ ក្នុងអត្រាកំណើន ៥១,៩%។ ក៏ប៉ុន្តែតាមការវិភាគកម្រិតនៃភាពក្រីក្រតាមភូមិនីមួយៗវិញ យើងបានរកឃើញថា ផ្ទុយពីអ្នកភូមិពាក់ព័ន្ធដទៃទៀតដែលមានកម្រិតជីវភាពធូរធារជាងមុន ប្រជាពលរដ្ឋនៅភូមិស្វាយជ្រុំបែរជាមានកម្រិតជីវភាពធ្លាក់ចុះដុនដាបទៅវិញ ព្រោះប្រាក់ចំណូលមធ្យមប្រចាំថ្ងៃរបស់ពួកគាត់គឺបានត្រឹមតែ ២៨០៤,៦០រៀល/ម្នាក់/ថ្ងៃប៉ុណ្ណោះ ពោលគឺទាបជាងកម្រិតបន្ទាត់នៃភាពក្រីក្ររហូតដល់ជិត២ដង ជាមួយនឹងអត្រាអវិជ្ជមាន -៣៥%។

**២៣.** ផ្លូវលំក្នុងឃុំថ្មីជាផ្លូវគ្រួសក្រហមខ្សាច់ភ្នំមានប្រវែង ១៥គ.ម មានសភាពទ្រុឌទ្រោមដោយសារទឹកភ្លៀង និងទឹកជំនន់ហូរកាត់។ ក្នុងឃុំកន្ទួតវិញមានផ្លូវជាតិលេខ៧ ក្រាលកៅស៊ូមានប្រវែង ១៧គ.ម ផ្លូវបេទីមីណឹមានប្រវែង ២៧០០០ម៉ែត្រ និងផ្លូវគ្រួសក្រហមខ្សាច់ភ្នំមានប្រវែង ៣០គ.ម។ ប៉ុន្តែប្រជាជននៅក្នុងតំបន់ដីសម្បទាននោះ នៅជួបប្រទះនូវការលំបាកក្នុងការធ្វើដំណើរពីភូមិនិមួយៗ ទៅកាន់ផ្លូវជាតិ មណ្ឌលសុខភាព និងសាលារៀន។ ជាក់ស្តែងក្នុងឃុំថ្មី ផ្លូវទៅកាន់ភូមិប្បៀរមានសភាពទ្រុឌទ្រោម និងជាប់ផុងដោយអន្លើ ដែលបង្កឲ្យមានការលំបាកក្នុងការធ្វើដំណើរ ហើយប៉ះពាល់ដល់ការធ្វើដំណើរទៅសិក្សារបស់កុមារ និងការប្រកបរបរផ្សេងៗទៀត ក៏ដូចជាការធ្វើទំនាក់ទំនងអាជីវកម្មជាមួយសហគមន៍ផ្សេងៗក្នុងតំបន់ ឬនៅតំបន់ផ្សេងៗផងដែរ។

**២៤.** ចំណែកឯការសិក្សាអប់រំនៅក្នុងឃុំទាំងពីរវិញ សិស្សានុសិស្សមានការលំបាកក្នុងការទទួលបាននូវការសិក្សាមួយខ្ពស់ ដោយសារតែមិនមានអនុវិទ្យាល័យនៅជិតភូមិរបស់គាត់ គឺមាននៅតែទីប្រជុំជនឃុំឯណោះ ដែលមានចម្ងាយជាមធ្យមប្រមាណជា ៥,៤គ.ម។ យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំថ្មីឆ្នាំ ២០១៣ បានឲ្យដឹងថា នៅក្នុងឃុំថ្មីមានមតេយ្យសាលា០២កន្លែង បឋមសិក្សាមានចំនួន ០៨ មាន២៥បន្ទប់ ស្មើនឹង ៥០ថ្នាក់ និងអនុវិទ្យាល័យមាន ០១ មាន០៥បន្ទប់ ស្មើនឹង០៥ថ្នាក់ ប៉ុន្តែមិនមានវិទ្យាល័យទេ។ ឯនៅក្នុងសៀវភៅឯកសារព័ត៌មានស្តីពីស្ថានភាពឃុំកន្ទួតឆ្នាំ២០១៤វិញ បានបង្ហាញថា ឃុំកន្ទួតមាន មតេយ្យសាលាចំនួន ០១កន្លែង បឋមសិក្សាមានចំនួន ០៦ មាន២៤បន្ទប់ ស្មើនឹង ៤៦ថ្នាក់ អនុវិទ្យាល័យ មាន ០១ មាន០៦បន្ទប់ ស្មើនឹង០៦ថ្នាក់ និងមានវិទ្យាល័យ០១ មាន០៧បន្ទប់ ស្មើនឹង ០៦ថ្នាក់។

**២៥.** យោងតាមការធ្វើសម្ភាសន៍តាមភូមិបានបង្ហាញថា មេគ្រួសារនៅឃុំពាក់ព័ន្ធទាំងពីរដែលមិនបានរៀនសូត្រសោះមាន២៥,៩%, មុនមត្តេយ្យសិក្សាមាន៣,១%, ត្រឹមមត្តេយ្យសិក្សាមាន ៣,១%, មិនចប់បឋមសិក្សាមាន ៥១,២%, ចប់បឋមសិក្សាមាន ៤,៩%%, មិនចប់អនុវិទ្យាល័យ មាន ៨,៦%, ចប់អនុវិទ្យាល័យមាន ០,៦%, មិនចប់វិទ្យាល័យមាន ១,៩%, ចប់វិទ្យាល័យ មាន ០,៦%, មិនចប់មហាវិទ្យាល័យ -គ្មាន, ចប់មហាវិទ្យាល័យ -គ្មាន, មិនចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ- គ្មាន, ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន។ ចំណែកឯសមាជិកគ្រួសារដែលមិនបានរៀនសូត្រសោះមាន ២០,៦%, មុនមត្តេយ្យសិក្សាមាន ៣,៧%, ត្រឹមមត្តេយ្យសិក្សាមាន ៤,៦%, មិនចប់បឋមសិក្សាមាន ៥៣,១%, ចប់បឋមសិក្សាមាន ៤,៨%, មិនចប់អនុវិទ្យាល័យមាន ៨,៩%, ចប់អនុវិទ្យាល័យមាន ១,៤%, មិនចប់វិទ្យាល័យមាន ១,៥%, ចប់វិទ្យាល័យមាន ១,១%, មិនចប់មហាវិទ្យាល័យមាន ០,១%, ចប់មហាវិទ្យាល័យមាន ០,១%, មិនចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន, ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ -គ្មាន។

**២៦.** លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា កុមារទាំងប្រុសទាំងស្រី អាយុចាប់ពី១៤ឆ្នាំឡើងទៅមានអត្រាបោះបង់ចោលនូវការសិក្សាខ្ពស់ខ្លាំង (៧១,៣%) នៅសល់តែចំនួនតិចតួច (២៨,៧%) ប៉ុណ្ណោះដែលនៅរៀនបន្ត។ មូលហេតុនៃការបោះបង់ចោលនូវការសិក្សានេះ មានដូចជា៖ ការរៀបការ គឺមានអត្រាខ្ពស់ជាងគេ (៤១,២%) បន្ទាប់មកគឺដើម្បីចូលធ្វើការងាររកកម្រៃជួយសម្រួលដល់បន្ទុកគ្រួសារ (២១,៦%) (មូលហេតុនេះគឺដូចគ្នាជាមួយនឹងលទ្ធផលពីការធ្វើការពិភាក្សាជាក្រុមដែរ), ដោយសារសាលានៅឆ្ងាយពេក (១៦,៦%), ការខ្វះខាតថវិកាក្នុងការបន្តការសិក្សា (១០,៣%) ហើយ ១០,១% ដោយសារតែនៅក្មេងពេកមិនទាន់គ្រប់អាយុចូលរៀន ឬចាស់ពេក និង០,២% ដោយសារមានជម្ងឺ។

**២៧.** នៅក្នុងឃុំកន្ទួត និងឃុំថ្មីសុទ្ធតែមានមណ្ឌលសុខភាពទាំងអស់ ប៉ុន្តែមណ្ឌលសុខភាពទាំងនោះស្ថិតនៅទីប្រជុំជនឃុំ ដែលឆ្ងាយពីភូមិពាក់ព័ន្ធទាំងនោះ ដូចជាភូមិអាលចស្ថិតនៅចម្ងាយ ១០គ.មពីមណ្ឌលសុខភាព និង៣០គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ. ភូមិល្ងៀរមានចម្ងាយ ២៥គ.មពី មណ្ឌលសុខភាព និង៥៣គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ, ភូមិក្រសាំងមានចម្ងាយ ១គ.មពីមណ្ឌលសុខភាព និង៣៦គ.មពីមន្ទីរពេទ្យបង្អែកខេត្តក្រចេះ, ភូមិថ្មីមានចម្ងាយ ៥គ.មពីមណ្ឌលសុខភាព និង ៣២.៥គ.មពិមន្ទីរពេទ្យបង្អែកខេត្តក្រចេះ ឯភូមិស្វាយជ្រុំវិញមានចម្ងាយ ៨គ.មពីមណ្ឌលសុខភាព និង៣៦គ.មពី

Draft

មន្ទីរពេទ្យបង្អែកខេត្តក្រចេះ។ នៅក្នុងភូមិទាំងនេះមានពេទ្យឯកជន ដែលស្ថិតនៅក្នុងភូមិតែម្តង ប៉ុន្តែពេទ្យឯកជននេះអាចព្យាបាលបានតែជម្ងឺស្រាលៗ ហើយយកតម្លៃសេវាព្យាបាលខ្ពស់។

**២៨.** ប្រជាជនក្នុងតំបន់ពាក់ព័ន្ធនោះ ៥៦,៨% មានជម្ងឺញឹកញាប់, ២៧,២% មានជម្ងឺម្តងម្កាល, ២,៥% តែងតែឈឺជាប្រចាំក្នុងកំឡុងពេល៥ឆ្នាំចុងក្រោយ និងមានតែ ១៣,៦% ប៉ុណ្ណោះដែលមានសុខភាពល្អធម្មតា។ ជម្ងឺដែលប្រជាពលរដ្ឋរស់នៅក្នុងឃុំពាក់ព័ន្ធទាំងពីរជួបប្រទះញឹកញាប់ជាងគេគឺ ២៦,៩% ជាជម្ងឺរាគរូស និងគ្រុនពោះវៀន, ២០,៣% ជាជម្ងឺគ្រុនចាញ់, ១៩% ជាជម្ងឺរលាកក្រពះ ពោះវៀន, ១៥,៥% ជាជម្ងឺផ្តាសាយ គ្រុនក្តៅ ជម្ងឺផ្លូវដង្ហើម, ៦,៨% ជាជម្ងឺសន្លាក់ដៃជើង, ៤,៩% ជាជម្ងឺភ្នែក ច្រមុះ ត្រចៀក បំពង់ក, ៤,៦% ជាជម្ងឺបេះដូង លើសឈាម ស្ទះសរសៃឈាម, ១,៣% ជាជម្ងឺទឹកនោមផ្អែម និង០,៧% ជាជម្ងឺរបេង។ ជម្ងឺគ្រុនចាញ់នៅតែជាបញ្ហាគួរឲ្យចាប់អារម្មណ៍ ទោះបីអ្នកខ្លះមិនបានចូលព្រៃក៏ដោយ។

**២៩.** យោងតាមឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៣ ប្រជាពលរដ្ឋក្នុងឃុំថ្មីប្រមាណជា ២០៧ គ្រួសារ (៩,៨៣%) ប៉ុណ្ណោះដែលមានបង្គន់អនាម័យប្រើប្រាស់។ ភាគរយគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មាន៖ ភូមិក្រសាំង ៨៩,៣%, ភូមិប្អៀរ ៩២,១%, ភូមិស្វាយជ្រុំ ៨៨,៧%, ភូមិថ្មី ៩៣,៩% និងភូមិត្នោត ៩១,៧%។ ដូចគ្នានេះដែរ ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០១៤ បានបញ្ជាក់ថា នៅក្នុងឃុំកន្ទួតមានប្រជាពលរដ្ឋតែ ១៥៩គ្រួសារ ឬស្មើនឹង ១០,៧២% ប៉ុណ្ណោះដែលមានបង្គន់អនាម័យ និង១៣៧គ្រួសារ ឬស្មើនឹង ៩,២៤% ប្រើប្រាស់បង្គន់មានបច្ចេកទេស ក្នុងនោះអ្នកភូមិអាលចប្រមាណជា ៨.៦% មានលទ្ធភាពប្រើប្រាស់បង្គន់មានបច្ចេកទេស ប៉ុន្តែនៅភូមិស្រែននដែលជាភូមិឧបសម្ព័ន្ធរបស់ភូមិអាលចវិញ មានគ្រួសារក្នុងចំនួនតិចតួចបំផុតដែលមានបង្គន់ប្រភេទនេះប្រើប្រាស់។

**៣០.** ក្រុមហ៊ុនបានអនុវត្តនូវបទបញ្ជាលេខ ០១ របស់រដ្ឋាភិបាល ដែលមានក្រុមនិស្សិតស្ម័គ្រចិត្តចុះមកវាស់វែងដោះស្រាយដីពាក់ព័ន្ធជាមួយប្រជាពលរដ្ឋរួចទាំងស្រុងហើយ។ ក្នុងនោះក្នុងអនុតំបន់ទី១ ក្រុមនិស្សិតបានចុះវាស់វែងកាត់នូវផ្ទៃដីចំនួន ១៨៥,៤១ហិកតា ក្នុងអនុតំបន់ទី២ បានកាត់ដីអស់ចំនួន ២៦៣,៩២ហិកតា ក្នុងអនុតំបន់ទី៣ បានកាត់ចេញនូវផ្ទៃដី ១១៨,៣៦ហិកតា និងក្នុងអនុតំបន់ទី៤ បានកាត់ចេញនូវផ្ទៃដី ១៣១,៤២ហិកតា ហើយដីទាំងអស់នេះត្រូវបានរៀបចំធ្វើប្លង់ និងប្រគល់សិទ្ធកាន់កាប់ជូនប្រជាពលរដ្ឋរួចអស់ហើយដែរ។

**៣១.** ប្រជាពលរដ្ឋភូមិប្អៀរបានទាមទារដីចំនួន ៥៤៥,២៤ហិកតា និងដី៤៣០ម៉ែត្រ ពីបង្គោលឡាក់មានចំនួនស្មើនឹង ១១,៥ហិកតា សម្រាប់ធ្វើផ្លូវថ្នល់សរុបស្មើនឹង៥៥៦,៧៤ហិកតា បន្ថែមទៀត ក្រុមហ៊ុនបានដោះស្រាយជាមួយនឹងអាជ្ញាធរដែនដីពាក់ព័ន្ធ និងប្រជាពលរដ្ឋភូមិប្អៀរនេះចំនួន ១១ដង រួចមកហើយ។ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ កន្លងទៅនេះ ដោយមានការសម្របសម្រួលពីអាជ្ញាធរខេត្ត ក្រុមហ៊ុនបានកាត់ដីចំនួន ៥៥៦,៧៤ហិកតា ឲ្យទៅប្រជាពលរដ្ឋភូមិប្អៀររួចហើយ។ បច្ចុប្បន្នក្រុមហ៊ុនក៏បានធ្វើការដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធក្នុងអនុតំបន់ទី៣ និងទី៤ ជាមួយប្រជាពលរដ្ឋបានចប់ជាស្ថាពរផងដែរ។

Draft

**៣២.** ក្រៅពីក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿកបានកាត់ដីចំនួន ៥៥៦,៧៤ហិកតា ឲ្យប្រជាពលរដ្ឋភូមិប៉ៀរចំនួន ២២៩គ្រួសារ ក្រុមហ៊ុនភូរៀងបានកាត់ដីចំនួន ១.០១៥ហិកតា និងក្រុមហ៊ុនម៉ូហ៊ីបាក៏បានកាត់ដីចំនួន ៥២០ហិកតាផងដែរ។ ក្រៅពីនេះ ប្រជាពលរដ្ឋភូមិប៉ៀរមានដីព្រៃសហគមន៍ចំនួន ៤៧០ហិកតាទៀត ដូច្នេះសរុបទៅ ពួកគាត់មានដីព្រៃ ២.៥៦១,៧៤ហិកតា សម្រាប់ប្រើប្រាស់ទៅថ្ងៃអនាគត។

**៣៣.** សំណល់រឹងដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រ មានដូចជា សំបកដប, សំបកកំប៉ុង, ប្រអប់ ឬថង់ប្លាស្ទិក។ ចំនួនបុគ្គលិក និងកម្មករអចិន្ត្រៃយ៍របស់ក្រុមហ៊ុនក្នុងពេលបច្ចុប្បន្ន និង ក្នុងពេលដំណើរការអាជីវកម្ម ប៉ាន់ស្មានថាមានចំនួន ៧០០នាក់ ហើយក្នុងម្នាក់ៗនឹងបញ្ចេញកាកសំណល់ចំនួន ៣០០ក្រាម/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រឹងដែលក្រុមហ៊ុននេះបញ្ចេញក្នុងមួយឆ្នាំ មានចំនួន ៣០០ក្រាម×៧០០នាក់×៣៦៥ថ្ងៃ = ៧៦,៦៥តោន/ឆ្នាំ។ ក្រៅពីសំណល់រឹងខាងលើនៅមានប្រភេទសំណល់រឹងផ្សេងៗទៀត មានដូចជា សំបកកង់ម៉ូតូ កង់ឡាន គ្រឿងបន្លាស់ចាស់ៗ ដែលប្រើការលែងកើត។ សំណល់នេះប៉ាន់ស្មានថាមានចំនួន១៥តោន/ឆ្នាំ។ ដូច្នេះ បរិមាណសំណល់រឹងដែលមិនអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រ សរុបមានចំនួន ៩១,៦៥តោន/ឆ្នាំ។

**៣៤.** សំណល់រឹងដែលអាចបំបែកបានតាមលក្ខណៈជីវសាស្ត្រ មានដូចជា សំណល់ពីផ្ទះបាយ។ ប៉ាន់ស្មានថាមនុស្សម្នាក់បញ្ចេញកាកសំណល់ចំនួន ៦០០ក្រាម/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រឹងដែលបញ្ចេញក្នុងមួយឆ្នាំមានចំនួន ៦០០ក្រាម×៧០០នាក់×៣៦៥ថ្ងៃ = ១៥៣,៣០តោន/ឆ្នាំ។ ប៉ុន្តែ ក្រោយពេលបំបែកជាតុ សំណល់នេះនឹងក្លាយទៅជាជីដែលមានប្រយោជន៍ដល់ការកែលម្អគុណភាពដី។ ក្រៅពីសំណល់រឹងដែលអាចបំបែកបានខាងលើ នៅមានសំណល់ដទៃទៀតដូចជាកាកសំណល់ឈើ (ជីវៈម៉ាស់)។ តាមការសិក្សាអំពីជីវៈម៉ាស់លើដី និងក្រោមដី (តារាង ៥.២៦) បង្ហាញថា ជីវៈម៉ាស់ក្រោមដីមានចំនួន ១៩,៧៣៥±៥,៣៨៣តោន/ហិកតា។ ដូច្នេះ នៅលើទំហំផ្ទៃដីអាជីវកម្មសរុប ៥.៤៣៦ហិកតា មានសំណល់ជីវៈម៉ាស់សរុបចោលនៅក្នុងដីចំនួន ១០៧.២៧៩,៤៦±២៩.២៦១,៩៨៨តោន។ សំណល់ទាំងនេះនឹងពុកផុយក្លាយជាមរោគផ្តល់ជីវជាតិដល់ដីនៅក្នុងរយៈពេលប្រមាណ ២-៤ឆ្នាំក្រោយ។ ចំណែកឯសំណល់ជីវៈម៉ាស់លើដីមានចំនួន ៦៥,៧៨៣±១៧,៩៤៣តោន/ហិកតា (គិតត្រឹមមែកទី១)។ តាមការប៉ាន់ស្មានជីវៈម៉ាស់ពីមែកទី១ រហូតដល់ចុងមានចំនួនប្រមាណ ១៩ភាគរយនៃជីវៈម៉ាស់សរុបលើដី ឬមានចំនួនប្រមាណ ១២,៥០តោន/ហិកតា។ ដូច្នេះ នៅលើទំហំផ្ទៃដីអាជីវកម្មសរុប ៥.៤៣៦ហិកតា មានសំណល់ជីវៈម៉ាស់លើដីសរុបចំនួន ៦៧.៩៥០តោន។

**៣៥.** សំណល់រាវដែលបញ្ចេញចោលក្នុងម្នាក់ៗ មានចំនួន ៣០លីត្រ/ថ្ងៃ។ ដូច្នេះ បរិមាណសំណល់រាវដែលក្រុមហ៊ុននេះបញ្ចេញក្នុងមួយឆ្នាំមានចំនួន ៣០លីត្រ×៧០០នាក់×៣៦៥ថ្ងៃ = ៧.៦៦៥ម$^{៣}$/ឆ្នាំ។

**៣៦.** ឧស្ម័នដែលបញ្ចេញពីសកម្មភាពគម្រោងនេះមាន ចំហេះប្រេងឥន្ធនៈរបស់គ្រឿងចក្រដែលប្រើសម្រាប់ឈូសព្រៃ និងការដុតព្រៃសម្អាតដី ដើម្បីដាំកៅស៊ូ។ ដើម្បីឈូសព្រៃសម្អាតដី ០១ហិកតា ត្រូវការប្រេងឥន្ធនៈចំនួន ២៥០លីត្រ (០១តោនប្រេងឥន្ធនៈមាន ១១៩០លីត្រ)។ ដូច្នេះ ដើម្បីសម្អាតព្រៃ ៥.៤៣៦ហិកតា ត្រូវការប្រេងឥន្ធនៈចំនួន ២៥០លីត្រ×៥.៤៣៦/១១៩០ = ១.១៤២តោន។ ចំហេះប្រេងឥន្ធនៈ ០១តោន ជាមួយនឹងកម្រិតចំហេះ (Octane) ៩៩ភាគរយ នឹងបំភាយឧស្ម័នកាបូនិក

Draft

៨៧,៣០៦៧៣គ.ក្រ[1]។ ដូច្នេះ ការប្រើប្រេងឥន្ធនៈចំនួន ១.១៤២តោន ត្រូវបំភាយឧស្ម័នកាបូនិកសរុបចំនួន ៩៩,៧០តោន។

**៣៨.** ក្នុងចំណោមសំណល់ជីវៈម៉ាស់លើដីសរុបចំនួន ៦៧.៩៥០តោន មានប្រមាណ៣០ភាគរយ ឬស្មើនឹង ២០.៣៨៥តោន យកទៅប្រើប្រាស់សម្រាប់សំណង់។ ជីវៈម៉ាស់ចំនួន ៧០ភាគរយ ឬ ៤៧.៥៦៥តោន ដែលនៅសល់មានប្រមាណ ២៥ភាគរយ ឬស្មើនឹង ១១.៨៩១,២៥តោន បានសេសសល់លើដី ក្រោយពីការប្រមូលគរនិងដុតចោល។ ចំណែកឯជីវៈម៉ាស់លើដីនៅសល់ចំនួន ៣៥.៦៧៣,៧៥តោន ត្រូវបានដុតចោលដើម្បីសម្អាតដីដាំកៅស៊ូ។ ការដុតជីវៈម៉ាស់ចំនួន ៣៥.៦៧៣,៧៥តោននេះ នឹងបំភាយនូវឧស្ម័នមួយចំនួនដូចខាងក្រោម[2]៖

| | | |
|---|---|---|
| ឧស្ម័នកាបូនិក | - | ៥៣.៩៧៤,០០តោន |
| មេតាន | - | ១៤៨,០០តោន |
| សូដ្យូមឌីអុកស៊ីដ | - | ១,៩៧តោន |
| សូដ្យូមម៉ូណូអុកស៊ីដ | - | ៤៩,២៣តោន |
| កាបូម៉ូណូអុកស៊ីដ | - | ២.៤៦១,៤៩តោន |
| NMVOC[3] | - | ២៩៩,៣៨តោន |

៣៩. **ថវិកាសំរាប់ការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន៖** ចាប់ពីឆ្នាំ ២០១៥តទៅ ក្រុមហ៊ុនបានគ្រោងថវិកាសរុបចំនួន **៣៤.០០០.០០**ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សម្រាប់អនុវត្តន៍**ផែនការគ្រប់គ្រងបរិស្ថាន** ដែលមានរយៈពេលស្មើនឹងអាយុកាលនៃការធ្វើវិនិយោគកំណត់ដោយច្បាប់ និងប្រើសម្រាប់ៈ (១) គ្រប់គ្រងតំបន់ទ្រនាប់ចំនួន **១០.៨០០,០០**ដុល្លារអាមេរិក (២) អនុវត្តន៍កម្មវិធីត្រួតពិនិត្យ និងវាយតម្លៃចំនួន **២៣.២០០,០០**ដុល្លារអាមេរិក។ ដោយឡែកចំពោះថវិកាបំរុង សម្រាប់ឧបត្ថម្ភសមាជិកគ្រួសារប្រជាពលរដ្ឋនៅក្នុងសហគមន៍ និងបុគ្គលិកកម្មករដែលមានគ្រោះថ្នាក់ដោយចៃដន្យនៅក្នុងរយៈពេលប្រតិបត្តិការ មិនបានដាក់បញ្ចូលទៅក្នុងតារាងតម្លៃប៉ាន់ស្មាន និងតាមដានពិនិត្យវាយតម្លៃនេះទេ។

៤០. **គម្រោងថវិកាសម្រាប់ការអភិវឌ្ឍន៍សហគមន៍ និងស្តារគុណភាពបរិស្ថាន៖** ចាប់ពីឆ្នាំ ២០១៥តទៅ ក្រុមហ៊ុនបានគ្រោងថវិកាសរុបចំនួន **៥៥.០០០.០០**ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សម្រាប់ការអភិវឌ្ឍន៍សហគមន៍ និងស្តារគុណភាពបរិស្ថាន ដែលមានរយៈពេលស្មើនឹងអាយុកាលនៃការធ្វើវិនិយោគកំណត់ដោយច្បាប់ និងប្រើសម្រាប់ៈ (១) អភិវឌ្ឍន៍សហគមន៍ចំនួន **២៥.០០០,០០**ដុល្លារអាមេរិក (២) ស្តារគុណភាពបរិស្ថានចំនួន **៣០.០០០,០០**ដុល្លារអាមេរិក។

៤១. តម្លៃខូចខាតរបស់ព្រៃល្បោះទំហំ ៥.៤៣៦ហិកតា នៃគម្រោងអភិវឌ្ឍន៍នេះ គឺ ៣៣.២០៨.៧៩៥ដុល្លារ និងតម្លៃខាតបង់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ៩២គ្រួសារ ពីការអាស្រ័យផល-អនុផលព្រៃឈើ

[1] ITCC
[2] Conversion and Emission factors, www.fao.org
[3] Non Methane Volatile Organic Compound

Draft

ក្នុងរយៈពេលមួយវដ្តផលិតកម្មកៅស៊ូ (២៥ឆ្នាំ) មានចំនួន **១.៨៧៦.៨០០ដុល្លារ** ដូច្នេះតម្លៃខូចខាតបណ្ដាលពីគម្រោងសរុបគឺ **៣៥.០៨៥.៥៩៥ដុល្លារ**។

៤២. ប្រាក់ចំណេញដែលក្រុមហ៊ុនទទួលបានគិតពីឆ្នាំទី-៩ត្រឹមឆ្នាំទី-២០គឺមានចំនួន **២៤.៨៤៩.០៣២ដុល្លារ**, ដើមកៅស៊ូចាស់ ៥.០០០ហិកតា (ជាផ្ទៃដីផលិតកម្មសុទ្ធមិនគិតហេដ្ឋារចនាសម្ព័ន្ធ) មានតម្លៃស្មើនឹង **២៥.០០០.០០០ដុល្លារ**, ប្រាក់ចំណូលផ្ទាល់ដែលបានពីការបង់ពន្ធអោយទៅរដ្ឋ គិតពីឆ្នាំទី-៦ ដល់ឆ្នាំទី ២០ មានចំនួន **៩.៨១៨.៦០០ដុល្លារអាមេរិក** និងប្រាក់ចំណាយទៅលើកម្លាំងពលកម្មក្នុងស្រុកសរុបរយៈពេល២០ឆ្នាំ គឺ **២៧.១៨៣.៨០០ដុល្លារអាមេរិក** ដូច្នេះតម្លៃសេដ្ឋកិច្ច និងសង្គមកិច្ចសរុបរបស់គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូគឺ **៨៦.៨៥១.៤៣២ដុល្លារ**។

៤៣. គម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូនេះក្នុងរយៈពេល២០ឆ្នាំ នឹងផ្ដល់នូវផលចំណេញចំនួន ៨៦.៨៥១.៤៣២ដុល្លារ-៣៥.០៨៥.៥៩៥ដុល្លារ = **៥១.៧៦៥.៨៣៧ដុល្លារ**។

៤៤. ការសិក្សាអំពីសន្និធិកាបូនក្នុងព្រៃល្បោះនៅក្នុងឃុំថ្មី និងឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ របស់ក្រុមហ៊ុន **ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)** បង្ហាញថា មធ្យមភាគសន្និធិកាបូនធម្មជាតិមុនពេលឈូសប្រែក្លាយដី មានបរិមាណតែ **៤២,៧៥៩តោន**/ហិកតា។ ការប្រែក្លាយដីព្រៃល្បោះរេចរឹលទំហំ **៥.៤៣៦ហិកតា** ក្នុងតំបន់នេះទៅជាចំការកៅស៊ូ នៅក្នុងរយៈពេលប្រមាណតែ ១០ឆ្នាំ ដំណាំកៅស៊ូនឹងផលិតសន្និធិកាបូនបានប្រមាណ **១៣៣តោន/ហិកតា**។ មានន័យថា សន្និធិកាបូនធម្មជាតិដែលមាននៅលើទីតាំងនេះមុនពេលអភិវឌ្ឍន៍ មានបរិមាណតិចជាងសន្និធិកាបូនរបស់ព្រៃកៅស៊ូដែលមានអាយុ១០ឆ្នាំទៅទៀត។ នៅឆ្នាំទី ៣០ ព្រៃកៅស៊ូអាចរក្សាសន្និធិកាបូនប្រមាណ ៤**៨៥តោនក្នុងមួយហិកតា** ឬមានបរិមាណប្រមាណ **១១,៣៤ដង** ច្រើនជាងមធ្យមភាគសន្និធិកាបូនរបស់ ព្រៃធម្មជាតិក្នុងពេលបច្ចុប្បន្ន។

៤៥. តម្លៃពាណិជ្ជកម្ម និងជីវៈចម្រុះរបស់ព្រៃធម្មជាតិក្នុងតំបន់នេះមានការធ្លាក់ចុះខ្លាំងទាំងនៅក្នុងព្រៃការពារ និងទ្រនាប់ព្រៃរក្សាទុកតាមប្រព័ន្ធផ្លូវទឹក។ ដូច្នេះ ការដាំឈើពាណិជ្ជកម្ម (ផ្ចឿក ឈើទាល និងគគីរ) ចំនួន ៥.០០០ដើម/ឆ្នាំ ឬ៣០០.០០០ដើម ក្នុងរយៈពេល៦០ឆ្នាំ នឹងនាំមកទាំងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងបរិស្ថានផងដែរ។

៤៦. តាមការពិនិត្យលទ្ធផលនៃការសិក្សា និងស្ថានភាពជាក់ស្ដែងនៅលើទីតាំងនៃគម្រោងវិនិយោគបានឲ្យដឹងថា៖ ព្រៃនៃតំបន់គម្រោងជាព្រៃដែលបានទទួលរងនូវការទន្ទ្រានកាប់ឈើអនាធិបតេយ្យ ជាព្រៃរេចរឹលបាន និងកំពុងឈានទៅរកការបាត់បង់ ធ្វើឲ្យប្រជាពលរដ្ឋក្នុងតំបន់គម្រោង ពិសេសជនជាតិដើមភាគតិច ដែលរស់នៅពឹងលើធនធានធម្មជាតិតែម្យ៉ាងនៅក្នុងតំបន់នោះ មានជីវភាពកាន់តែក្រីក្រទៅៗ តែងជួបប្រទះនូវការខ្វះខាត ពេលមានជម្ងឺឈឺថ្កាត់ និងស្ត្រីមានផ្ទៃពោះ ត្រូវធ្វើដំណើរឆ្ងាយទៅរកសេវាព្យាបាល និងគាំពារ ដោយឆ្លងកាត់តាមផ្លូវព្រៃលំបាកដែលទ្រុឌទ្រោម (ភូមិប្អៀរ ភូមិឧបសម្ព័ន្ធយ៉ៃ ភូមិឧបសម្ព័ន្ធស្រែននជាដើម)។ បន្ទាប់ពីមានការផ្ដល់សិទ្ធិប្រទានដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុន ដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ) ហើយក្រុមហ៊ុនបានចាប់ផ្ដើមអនុវត្តនូវការឈូសឆាយព្រៃ ដើម្បីរៀបចំសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធផ្លូវ និងដាំដំណាំកៅស៊ូមក ប្រជាពលរដ្ឋក្នុងតំបន់មានភាពងាយស្រួលជាងមុន ដោយអាចប្រើប្រាស់ផ្លូវរបស់ក្រុមហ៊ុនក្នុងការធ្វើដំណើរឆ្លងកាត់ពីភូមិទៅកាន់ទីប្រជុំជន សាលា

Draft

រៀន មណ្ឌលសុខភាព និងការដឹកជញ្ជូនផលិតផលទៅលក់នៅទីផ្សារទៀតផង។ ពិសេសជាងនេះទៅទៀត ក្រុមហ៊ុនវិនិយោគដោយមានការសហការរបស់អាជ្ញាធរខេត្តក្រចេះ បានធ្វើសម្បទានជាច្រើនក្នុងការដោះស្រាយបញ្ហាដីធ្លីពាក់ព័ន្ធ ការជួយបំពេញតម្រូវការតាមសំណូមពរផ្សេងៗ ក៏ដូចជាសំណូមពរនូវអាទិភាពការងាររបស់ប្រជាពលរដ្ឋ ដោយទទួលបាននូវប្រាក់កម្រៃពលកម្មទៀងទាត់មួយផងនោះ បង្កឲ្យលក្ខខណ្ឌនៃការរស់របស់ប្រជាពលរដ្ឋត្រូវបានកែលំអជាលំដាប់។ ទោះបីក្នុងតំបន់នេះទទួលរងនូវផលប៉ះពាល់អវិជ្ជមាន ធ្វើឲ្យខូចខាតដល់បរិស្ថាន និងសេដ្ឋកិច្ចសង្គមមួយចំនួន (មានបង្ហាញនៅក្នុងជំពូកទី៩) យ៉ាងណាក៏ដោយ ដោយសារការអនុវត្តផែនការការងារដ៏ត្រឹមត្រូវរបស់ក្រុមហ៊ុន ដែលប្រកាន់យ៉ាងខ្ជាប់ខ្ជួនតាមវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទាំងឡាយ តាមគោលការណ៍ណែនាំពីក្រសួងមានសមត្ថកិច្ច និងស្ថាប័នជំនាញពាក់ព័ន្ធនានា ក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហឿក បាននិងកំពុងមានដំណើរការរបស់ខ្លួនក្នុងទិសដៅអភិវឌ្ឍន៍សមស្រប ជាមួយនឹងការអភិរក្ស រក្សាលំនឹងបរិស្ថានឲ្យបានត្រឹមត្រូវផងដែរ។ ពុំអាចគណនាបានថា តើភាពងាយស្រួលដែលប្រជាពលរដ្ឋទទួលបាន ហើយនិងកំរិតជីវភាពទៀងទាត់សមរម្យមួយ មានតម្លៃប៉ុណ្ណានោះទេ? ប៉ុន្តែយើងគ្រាន់តែដឹងថា ទាំងនេះគឺជាចូលរួមចំណែកក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងគោលបំណងសំខាន់ ដែលរាជរដ្ឋាភិបាលប្រាថ្នាចង់បានក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាទូទៅ។

## អនុសាសន៍

ចំពោះការធ្វើផែនការអភិវឌ្ឍន៍សហគមន៍ ក្រុមហ៊ុនចាំបាច់ត្រូវពិចារណាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោមជាអាទិភាព៖

- ក្រុមហ៊ុនត្រូវសហការជាមួយគណៈកម្មាធិការដោះស្រាយដីធ្លីថ្នាក់ខេត្ត ដើម្បីបំពេញ ឬអនុវត្តនិតិវិធី សំណើសុំចុះបញ្ជីធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុ និងធ្វើវិញ្ញាបនប័ត្រលើផ្ទៃដីទំហំ ៥.៤៣៦ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រឃុំកន្ទួត និងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។
- ក្រុមហ៊ុនត្រូវបង្កើតឡើង ឬស្តារឡើងវិញនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ឲ្យបានសមស្របតាមតម្រូវការជាក់ស្តែងក្នុងភូមិនីមួយៗដូចជា សេវាសុខភាពសាធារណៈ សាលារៀន (កម្រិតមធ្យមសិក្សា) អណ្តូងទឹកស្អាត បង្គន់អនាម័យ និងជាពិសេសត្រូវផ្តោតសំខាន់លើផ្លូវគមនាគមន៍ជាអាទិភាព សម្រាប់បង្កើនកម្រិតជីវភាពរស់នៅ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋមូលដ្ឋាន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- ការកំណត់ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ច តាមរយៈការជីកកាយចង្អូរធ្វើជាព្រំដីដែលកៀកទៅនឹងភ្លឺស្រែចម្ការអ្នកភូមិពេក គឺអាចបង្កអោយមានផលប៉ះពាល់លើការដាំដុះស្រូវ ដំណាំចម្ការផ្សេងៗ ដោយសារម្លប់ដើមកៅស៊ូ និងគ្រោះថ្នាក់ដល់គោក្របីរបស់ប្រជាពលរដ្ឋ។ ដូច្នេះក្រុមហ៊ុនគួរជីកកាយចង្អូរព្រំប្រទល់អោយនៅឆ្ងាយពីព្រំដីស្រែចម្ការរបស់ពួកគាត់តាមលទ្ធភាពអាចធ្វើបាន ឬក៏គួរបោះតែបង្គោលសម្គាល់នៅតាមទីតាំងទាំងឡាយណាដែលមានដីស្រែចម្ការប្រជាពលរដ្ឋតាំងនៅ។

Draft

- ប្រជាពលរដ្ឋក្នុងភូមិដែលទទួលរងផលប៉ះពាល់ គួរមានសិទ្ធិអាទិភាពសម្រាប់ការជ្រើសរើសអោយចូលបម្រើការងារជាពលករ ឬកម្មករបម្រើការក្នុងក្រុមហ៊ុន។ ព្រោះតាមលទ្ធផលពីការអង្កេតរកឃើញថា អ្នកភូមិភាគច្រើនមានបំណងចង់ធ្វើការអោយក្រុមហ៊ុន ដើម្បីបានប្រាក់ចំណូលបន្ថែមពីការធ្វើស្រែចម្ការ។

- ក្រុមហ៊ុនគួររៀបចំអោយមានស្តង់ដាការងារសមស្របសម្រាប់ពលករ កម្មករដែលធ្វើការអោយក្រុមហ៊ុន រួមបញ្ចូលទាំងការជ្រើសរើសបុគ្គលិក លក្ខខណ្ឌការងារសមស្រប ការផ្តល់នូវកន្លែងស្នាក់នៅ ឬកន្លែងសម្រាកសមរម្យ អនាម័យបរិស្ថាននៅកន្លែងធ្វើការ និងស្តង់ដាប្រាក់បៀវត្សសមស្របផងដែរ។

- ក្រុមហ៊ុនគួរត្រូវរៀបចំផែនការអភិវឌ្ឍន៍សហគមន៍អោយបានសមស្រប ដើម្បីជំនួសការបាត់មូលដ្ឋានសេដ្ឋកិច្ចរបស់ប្រជាជនខ្មែរទូទៅ និងគួរមានផែនការអភិវឌ្ឍន៍ជនជាតិភាគតិចដាច់ដោយឡែកមួយ ព្រោះពួកគាត់ត្រូវបានចាត់ទុកជាក្រុមជនដែលងាយរងគ្រោះ។

- នៅក្នុងដំណើរប្រតិបត្តិការគំរោងសាមុីវិនិយោគិន ត្រូវតែអនុវត្តផែនការគ្រប់គ្រងបរិស្ថានទៅតាមវិធានការនានាដូចមានកំណត់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងផែនការត្រួតពិនិត្យបរិស្ថាន ដូចបានពណ៌នានៅក្នុងតារាង ៨-១ ហើយស្ថាប័នជំនាញ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវតាមដានពិនិត្យ និងវាយតំលៃទៅលើសកម្មភាពនៃការអភិវឌ្ឍន៍របស់វិនិយោគិនជាប្រចាំ ទៅតាមកម្មវិធីដូចមានកំណត់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

- ចំពោះការបង្កើតរោងចក្រកែច្នៃផលិតផលកៅស៊ូ ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ដាច់ដោយឡែកមួយ ដើម្បីដាក់ជូនក្រសួងបរិស្ថាន ពិនិត្យផ្តល់យោបល់ នឹងសម្រេច មុនពេលចាប់ផ្តើមសាងសង់ ធ្វើដូច្នេះគឺដើម្បីឱ្យស្របទៅតាមខ្លឹមសារអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

..., ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥
នាយកក្រុមហ៊ុនដូទីសាយហ្គន-ប៊ិញហ្វឿក (អេស ប៊ី ខេ)

ភ្នំពេញ, ថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០១៥
នាយកក្រុមហ៊ុនអ៊ុនវ៉ាយរ៉ូថេក សឺវីស

ENVIROTECH SERVICE Co., Ltd.
KINGDOM OF CAMBODIA